# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃ ចន្ទ ៩ កើត ខែ ផល្គុន ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២៤

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីបើកដំណើរការកម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថលជំនាន់ទី ៣

នាថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២៤ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (ម.ធ.ត.) បានរៀបចំពិធីបើកដំណើរការ **កម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថល វគ្គកាលទី៣** ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត តាំង ចូនលី នាយកមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"** ព្រមជាមួយការចូលរួមពីសំណាក់អ្នកតំណាងនៃសហគ្រិនខ្មែរ, អ្នកតំណាងនៃធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ (ធនាគារ ABA), ស្ថាប័នដៃគូ និង ក្រុមធុរកិច្ចថ្មីជាច្រើនផងដែរ។

ពិធីបើកដំណើរការនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង ប្រកាសជាផ្លូវការនូវការរៀបចំកម្មវិធីពន្លឿនអាជីវកម្ម នាដើម ឆ្នាំ ២០២៤ របស់មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និង ជាការអបអរសាទរចំពោះក្រុមធុរកិច្ចថ្មីឌីជីថលទាំង ១៤ ក្រុម ដែលត្រូវបានជ្រើសរើសឱ្យចូលរួមក្នុង **កម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថលវគ្គកាលទី៣**។ ឆ្លៀតក្នុងឱកាសនៃពិធីបើកដំណើរការនេះផងដែរ, ម.ធ.ត. ក៏បានបង្ហាញនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះដៃគូគាំទ្រដូចជា អ្នកសហការរៀបចំ, អ្នកឧបត្ថម្ភធំ, និង ដៃគូផ្សព្វផ្សាយដែលចូលរួមចំណែកជាមួយ ម.ធ.ត. ក្នុងកម្មវិធីនេះ។ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (ម.ធ.ត.) នៅតែបន្តការប្តេជ្ញាចិត្តក្នុងការជួយគាំទ្រដល់ការអភិវឌ្ឍធុរកិច្ចថ្មីនៅកម្ពុជា តាមរយៈការរៀបចំកម្មវិធីពន្លឿនអាជីវកម្មថ្នាលនេះ និង កម្មវិធីសហគមន៍ជាច្រើន ដើម្បីជួយជំរុញបរិវត្តកម្មឌីជីថល នៅក្នុងប្រទេសកម្ពុជា ឱ្យស្របតាមក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយវិស័យសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា។ ដូចនេះគ្នាដែរ កម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថលវគ្គកាលទី ៣ ត្រូវបានរៀបចំឡើងដើម្បីគាំទ្រធុរកិច្ចថ្មីដែលបាននឹងកំពុងអភិវឌ្ឍថ្នាលឌីជីថល ឬ ផ្តល់ដំណោះស្រាយបែបឌីជីថលប្រកបដោយនវានុវត្តន៍ឆ្លើយតបនឹងតម្រូវការទីផ្សារ កម្មវិធីកម្មវិធីពន្លឿនអាជីវកម្មនេះនឹងផ្តោតលើគោលបំណងចំនួន ៣ រួមមាន៖ ១) ផ្តល់ឱកាសដល់នវានុវត្តជន និង ធុរជន ដែលបាននិងកំពុងអភិវឌ្ឍថ្នាលឌីជីថល ឬ ដំណោះស្រាយឌីជីថល ដែលមានសក្តានុពលឆ្លើយតបនឹងតម្រូវការទីផ្សារទទួលបានការគាំទ្រ

និង បំពេញបន្ថែមនូវជំនាញដែលខ្វះខាត, ២) ជំរុញធុរកិច្ចថ្មីឌីជីថល ដែលមានសក្តានុពលឱ្យសម្រេចបាននូវគោលដៅទីផ្សារ និង ផ្សារភ្ជាប់កិច្ចសហប្រតិបត្តិការរវាងក្រុមធុរកិច្ចថ្មី និង ដៃគូសំខាន់ៗដូចជា វិនិយោគិន, អ្នកផ្តល់សេវាកម្ម, និង ដៃគូអភិវឌ្ឍជាដើម, និង ៣) បង្កើនអន្តរកម្មរវាងភាគីពាក់ព័ន្ធក្នុងប្រព័ន្ធអេកូឡូស៊ីនៃប្រទេសកម្ពុជា តាមរយៈការសម្របសម្រួលនូវទំនាក់ទំនងរវាងភាគីពាក់ព័ន្ធខាងក្នុង និង ខាងក្រៅ។

គួរបញ្ជាក់ថា ក្រុមធុរកិច្ចថ្មីដែលចូលរួមក្នុងកម្មវិធីនឹងទទួលបានអត្ថប្រយោជន៍ជាច្រើនដូចជា៖ ១) ការបណ្តុះបណ្តាល និង ការតម្រង់ទិសពីអ្នកជំនាញ, ២) ការបង្កើតបណ្តាញទំនាក់ទំនងជាមួយដៃគូពាក់ព័ន្ធផ្សេងៗ ដូចជា វិនិយោគិន, អ្នកផ្តល់សេវាកម្ម, និង ដៃគូអភិវឌ្ឍជាដើម, ៣) ការិយាល័យធ្វើការរួមគ្នា និង ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធ ដូចជាការសាកល្បងការទូទាត់ប្រាក់ឌីជីថល (Digital Payment Sandbox), CamDX, CamDigiKey, Khmer OCR, Semantic Search, ការចុះឈ្មោះអាជីវកម្មតាមប្រព័ន្ធអនឡាញ, ថ្នាលឌីជីថលធុរកិច្ចថ្មីកម្ពុជា, ៤) ឱកាសទទួលបានឥណទានពពក ដើម្បីប្រើប្រាស់សេវាកម្ម AWS ដែលមានតម្លៃស្មើនឹង ៥ ពាន់ដុល្លារអាមេរិក, ៥) ការទំនាក់ទំនងជាមួយវិនិយោគិន, និង ៦) ការទទួលបានទុនវិនិយោគដែលមិនយកភាគហ៊ុនជាដើមពីកម្មវិធី។ ហើយអត្ថប្រយោជន៍ខាងលើនេះនឹងសម្រេចទៅបានក្នុងរយៈពេលសរុប ១៤ សប្តាហ៍ ដែលត្រូវបានបែកចែកជា ៣ ដំណាក់កាលធំៗរួមមាន៖ ១) វគ្គជំរុំចាប់ផ្តើម (Bootcamp), ២) វគ្គពន្លឿនអាជីវកម្ម និង ៣) ថ្ងៃបង្ហាញជាសាធារណៈ (Demo Day) ដែលជាវគ្គផ្តាច់ព្រ័ត្រក្នុងកម្មវិធី។

គួរបញ្ជាក់ផងដែរថា កម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថល ជំនួរកាលទី៣ ត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ", ដោយមានការសហការរៀបចំកម្មវិធីដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង សហគ្រិនខ្មែរ រួមទាំង អ្នកឧបត្ថម្ភកម្មវិធីធំ៖ ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (ABA) និង ដៃគូផ្សព្វផ្សាយ៖ Fresh News និង AMS។

*ព័ត៌មានទំនាក់ទំនង៖*

*- អំពីកម្មវិធី៖ កញ្ញា អ៊ឹម ចន្ទី, លេខទូរសព្ទ៖ +៨៥៥ ៩៦ ២៧ ៦៣ ៥៧៨*

*- សម្រាប់ព័ត៌មានបន្ថែម៖ https://dpa.techostartup.center/*